# ការបន្ទ្រច់ ?

កឹម សុខា ជា នយៈជន មាន គុណសម្បត្តិ ជា រដ្ឋបុរស នឹង អាច ជា អ្នក ដឹកនាំ ជាតិ នៅ ពេល អនាគត។ បើ ធៀប នឹង សម រង្ស៊ី អ្នក ទាំង ពីរ មាន តួ នាទី ជួយ បន្ថែម គ្នា ទៅ វិញ ទៅ មក ក្នុង ការតស៊ូ ដើម្បី ជំរឿន នៃ ប្រជាធិបតី នៅ ស្រុក ខ្មែរ។ បើ នរៈនោះ ប្រជែង គ្នា វិញ វា ជា ដំណើរ នាំ យក ជ័យជំនះ ទៅ រក បរាជ័យ ដែល ជា បំណង របស់ របប ក្រុង ភ្នំពេញ។ ប៉ុន្តែ កឹម សុខា និង សម រង្ស៊ី សព្វ ថ្ងៃ ស្ថិត នៅ ក្នុង ស្ថានភាព ខុស គ្នា, ម្នាក់ នៅ ក្នុង ក្រោម សម្ពាធ នៃ របប ផ្តាច់ការ ដែល ខាឃាំង គាត់ មិន ឱ្យ មាន សេរីភាព ធ្វើ សកម្មភាព នយោបាយ, ម្នាក់ ទៀត ជា ឥស្សរជន មាន លទ្ធភាព ដឹកនាំ ការតស៊ូ ប្រឆាំង នឹង របប ផ្តាច់ការ ពី ក្រៅ ប្រទេស។ ភាព មិន ដូច គ្នា នេះ វា ក៏ ជា ការទូទាត់ នៃ កម្លាំង តស៊ូ នៅ ក្នុង និង ក្រៅ ស្រុក។ ដូច្នេះ ការបន្ត ការតស៊ូ វា មិន អាច នៅ រង់ចាំ កឹម សុខា អកម្ម បាន នោះ ឡើយ។ នៅ ពេល ដែល កឹម សុខា ជា ឥស្សរជន ឡើង វិញ អាច ជ្រើស ផ្លូវ នយោបាយ របស់ គាត់ : បន្ត ការតស៊ូ ឬ ស្វែង រក ការផ្សះផ្សា ជា មួយ របប ផ្តាច់ការ, នៅ ពេល នោះ ឯង គាត់ ជា អ្នក ទទួល ខុស ត្រូវ ព្រោះ ជម្រើស ទី២ វា ជា ផ្លូវ បែក, ផ្លូវ ស្តាំ ទៅ រក ជោគជ័យ, ផ្លូវ ឆ្វេង ទៅ រក បរាជ័យ ផ្ទាល់ ខ្លួន ដ្បិត ផ្លូវ ជោគជ័យ ជា ផ្លូវ គ្មាន ជម្រើស របស់ អ្នក ប្រជាធិបតេយ្យ។ ដូច្នេះ កម្លាំង បង្គ្រប់ របស់ កឹម សុខា វា នៅ លើ ជម្រើស ជា ជំនួយ របស់ គាត់៕

ឧប សៅ សទ្ធា គំនិត ១១ ធ្នូ ២០១៩